ការតភ្ជាប់សហគមន៍
របស់យើង

ព័ត៌មានបច្ចុប្បន្នភាព

# កិច្ចការដែលត្រូវធ្វើ ប្រសិនបើរថយន្តរបស់អ្នកត្រូវបានគេសណ្តោងចេញ?

រថយន្តរបស់អ្នកត្រូវបានគេសណ្តោងចេញ និងឃុំទុក ពីព្រោះវាបានចតនៅក្នុងតំបន់សណ្តោងចេញ ហើយអ្នកអាចទទួលការផាកពិន័យ បន្ថែមលើថ្លៃដោះលែងរថយន្ត។

តំបន់ហាមមិនឱ្យចតរថយន្ត និងតំបន់សណ្តោងរថយន្តចេញ ជួយរក្សាចរាចរណ៍ និងកាត់បន្ថយការស្ទះ ដោយការធានាថា ពុំមានរថយន្តចតនៅលើដងផ្លូវ ក្នុងអំឡុងពេលចរាចរណ៍មមាញឹក។

## ដំណើរការចំពោះការមិនគោរពច្បាប់ចរាចរណ៍

1. **អ្នកបើកបរត្រូវបង់ថ្លៃដោះលែងរថយន្ត**

- ដើម្បីឱ្យគេដោះលែងរថយន្តរបស់អ្នក អ្នកត្រូវតែផ្តល់នូវឯកសារបញ្ជាក់អត្តសញ្ញាណ និងបង់ថ្លៃដោះលែងរថយន្ត។
- ប្រសិនបើអ្នកជឿជាក់ថា រថយន្តរបស់អ្នកមិនគួរត្រូវបានគេសណ្តោងចេញទេ អ្នកអាចស្នើសុំការពិនិត្យឡើងវិញ បន្ទាប់ពីអ្នកបានបង់ថ្លៃដោះលែងរថយន្ត។
- អ្នកអាចដាក់ពាក្យសុំការពិនិត្យឡើងវិញ ដោយផ្អែកលើមូលដ្ឋាននៃកាលៈទេសៈពិសេស ហើយអ្នកត្រូវផ្តល់ព័ត៌មានលម្អិតអំពីពេលវេលា កាលបរិច្ឆេទ និងទីតាំងនៃកន្លែងសណ្តោង រួមជាមួយភស្តុតាងគាំទ្រ។
- ភ័ស្តុតាងសម្រាប់កាលៈទេសៈពិសេសអាចរួមមាន របាយការណ៍ លិខិត សេចក្តីថ្លែង ការបញ្ជូនសេចក្តីប្រកាសផ្លូវការ របាយការណ៍របស់ប៉ូលីស និងសេចក្តីជូនដំណឹងអំពីសុវត្ថិភាពអំពើហិង្សាក្នុងគ្រួសារ។
- ដើម្បីស្វែងយល់បន្ថែម សូមចូលមើលវិបសៃថ៍ VicRoads ហើយស្វែងរក 'tow away zones' (តំបន់សណ្តោងចេញ)។
- ដើម្បីស្នើសុំការពិនិត្យឡើងវិញ សូមសរសេរទៅកាន់៖ Clearway Towing Administrator, VicRoads, Locked Bag 9000, Kew Victoria 3101
- ផ្អែកលើព័ត៌មាន និងឯកសារគាំទ្រដែលបានផ្តល់ជូនក្នុងពាក្យសុំរបស់អ្នក VicRoads នឹងពិនិត្យមើលកាលៈទេសៈនៃការសណ្តោង ហើយជូនដំណឹងមកអ្នកអំពីលទ្ធផល។

2. **ម្ចាស់រថយន្តអាចទទួលការផាកពិន័យចំពោះការចតរថយន្តខុសច្បាប់**

- វាជាបទល្មើសក្នុងការចតរថយន្តនៅ តំបន់ហាមមិនឱ្យចតរថយន្ត និងតំបន់សណ្តោងរថយន្តចេញ ក្នុងអំឡុងពេលហាមមិនអោយចតរថយន្ត ហើយម្ចាស់រថយន្តដែលបានចុះបញ្ជី អាចទទួលការផាកពិន័យចំពោះការចតរថយន្តខុសច្បាប់ ចំពោះ 'ការឈប់នៅតំបន់ហាមមិនឱ្យចតរថយន្ត'។
- ការផាកពិន័យត្រូវបានផ្ញើតាមប្រៃសណីយ៍ទៅម្ចាស់រថយន្តដែលបានចុះបញ្ជី។ ប្រសិនបើនេះមិនមែនជាអ្នកទេ សូមប្រាកដថាអ្នកផ្តល់ព័ត៌មាននេះដល់ម្ចាស់រថយន្តដែលបានចុះបញ្ជី។

3. **ការបង់ប្រាក់ពិន័យរបស់អ្នក**

- ប្រសិនបើអ្នកបានទទួលការផាកពិន័យពីក្រសួងដឹកជញ្ជូន ហើយត្រូវការព័ត៌មានបន្ថែមអំពីដំណើរការនេះ សូមចូលមើលវិបសៃថ៍របស់ក្រសួងដឹកជញ្ជូន ហើយស្វែងរក 'clearways fine' (ការផាកពិន័យចំពោះការចតរថយន្តនៅ តំបន់ហាមមិនឱ្យចតរថយន្ត) ឬផ្ញើអ៊ីម៉ែលទៅ clearway.infringements@transport.vic.gov.au
- ប្រសិនបើអ្នកបានទទួលការផាកពិន័យពីសាលាក្រុង Yarra, Stonnington, Maribyrnong, Moreland, Darebin, Boroondara, Port Phillip និង/ឬម៉ែលប៊ិន អ្នកត្រូវទាក់ទងសាលាក្រុងដែលពាក់ព័ន្ធនោះដោយផ្ទាល់។

## សេវាកម្មអ្នកបកប្រែភាសា

ដើម្បីស្វែងយល់ពីអ្វីដែលត្រូវធ្វើ នៅពេលរថយន្តរបស់អ្នកត្រូវបានគេសណ្តោង សូមទូរស័ព្ទ ខ្សែទូរស័ព្ទព័ត៌មានពហុភាសារបស់ VicRoads លេខ (03) 9280 0783។

## សេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ

ប្រសិនបើអ្នកជាមនុស្សគថ្លង់ អន់ខ្សោយក្នុងការស្តាប់ ឬនិយាយមិនច្បាស់ សូមទូរស័ព្ទមកសេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ លេខ 1300 555 727 បន្ទាប់មកស្នើសុំលេខ 13 11 71។

STU_02919 02.21 អនុញ្ញាត និងបោះពុម្ពផ្សាយដោយ VicRoads 60 Denmark Street Kew Victoria 3101.